# ឌុច ផ្តោតទៅលើទីបញ្ចប់ មិនមែនមធ្យោបាយទេ

*ដោយ ឡូរ៉ា ម៉ាក់ដូណល់*
*ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩*
*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

## ការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរស-២១

*នេះគឺជាថ្ងៃដ៏អាប់អួរមួយនៅក្នុងអង្គសវនាការ ខណៈពេលដែលអង្គជំនុំជម្រះបន្តសួរសំណួរជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ឌុច) ទាក់ទិនពីប្រតិបត្តិការរបស់គុកទួលស្លែង (មន្ទីរស-២១) ដ៏សាហាវរបស់ខ្មែរក្រហមដោយផ្តោតទៅលើការសួរចម្លើយ និងវិធីសាស្ត្រធ្វើទារុណកម្មដែលប្រើប្រាស់មកលើអ្នកទោស ។*

*ក្រោយពីការសួរចម្លើយ សមមិត្ត ហ៊ី ដែលជាអនុប្រធានរបស់ ឌុច បានដាក់អ្នកទោសទៅតាមក្រុមអ្នកសួរចម្លើយទាំងបួនក្រុមផ្សេងៗគ្នា ដែលត្រូវបានរៀបចំឡើងដោយស្របទៅតាមវិធីសាស្ត្រធ្វើទារុណកម្មដែលអ្នកសួរចម្លើយត្រូវអនុវត្ត ។ ក្រុម«ត្រជាក់»មិនបានធ្វើទារុណកម្មឡើយ ប៉ុន្តែក្រុមសួរចម្លើយនេះព្យាយាមយល់ពីចិត្តរបស់អ្នកទោស ដើម្បីបង្ខំឲ្យអ្នកទោសឆ្លើយសារភាពពីបទល្មើសរបស់ខ្លួនប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ។ ឧបករណ៍ ធ្វើទារុណកម្មបានដាក់បង្ហាញឲ្យឃើញនៅក្នុងបន្ទប់សួរចម្លើយដើម្បីជះឥទ្ធិពលលើអ្នកទោស ។ ក្រុម«ក្តៅ»មាន«ដៃក្តៅ» ហើយជាទូទៅតែងតែវាយអ្នកទោសក្នុងរយៈពេលខ្លី ។ ចំណែកឯក្រុម«អង្កៀម»យកចិត្តទុកដាក់លើអ្នកទោសដែលចាត់ទុកថា មានសារសំខាន់សម្រាប់ការសួរចម្លើយរយៈពេលវែង ជួនកាលការសួរចម្លើយមានរយៈពេលជាច្រើនសប្តាហ៍ ឬច្រើនខែក៏មានដែរ ។ ជាចុងក្រោយ មានក្រុមពិសេសមួយធ្វើការសួរចម្លើយសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ ដែលចម្លើយសារភាពរបស់អ្នកទោសប្រភេទនេះចាត់ទុកថា មានសារសំខាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជា ពីព្រោះថា ចម្លើយសារភាពទាំងអស់នោះអាចមានជាប់ពាក់ព័ន្ធនឹងសមាជិកផ្សេងទៀតនៅក្នុងជួរអ្នកដឹកនាំ ។*

ក្នុងអំឡុងពេលដែល ឌុច ធ្វើជាអនុប្រធាន ហើយក្រោយមកក្លាយជាប្រធានមន្ទីរស-២១នេះ ឌុច មានការទទួលខុសត្រូវចំពោះការបណ្តុះបណ្តាលកម្មាភិបាលឲ្យចេះពីវិធីសាស្ត្រសួរចម្លើយ ។ បើទោះបីជា ឌុច មិនបានបង្រៀនពីវិធីសាស្ត្រធ្វើទារុណកម្មដោយផ្ទាល់ក៏ដោយ ក៏ ឌុច បានពិភាក្សាពីសារសំខាន់នៃការធ្វើទារុណកម្ម និងអនុញ្ញាតឲ្យធ្វើទារុណកម្មបួនប្រភេទ ៈ «ការវាយ»នឹងដំបងរំពាត់ឬក៏ដៃ ការធ្វើឲ្យថប់ដង្ហើមដោយថង់ប្លាស្ទិច ប្រកទឹកតាមច្រមុះ និងឆក់ខ្សែភ្លើង ។ ឌុច ទទួចនិយាយថា គាត់បានបង្គាប់ឲ្យអ្នកសួរចម្លើយទាញយកចម្លើយសារភាពដំបូង ដោយប្រើប្រាស់ការគំរាមដោយពាក្យសម្តី ហើយសម្រេចធ្វើទារុណកម្មសម្រាប់ពេលដែលចាំបាច់តែប៉ុណ្ណោះ ។ យ៉ាងណាមិញ ឌុច បានទទួលស្គាល់ថា មានតែអ្នកសួរចម្លើយម្នាក់គត់ដែលប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងបែបនេះ ខណៈពេលដែលអ្នកសួរចម្លើយដទៃទៀតបានប្រើប្រាស់ការធ្វើទារុណកម្មតាំងពីដំបូង ។ ក្នុងអំឡុងពេលសួរចម្លើយមួយទល់មួយជាមួយអ្នកទោស ព្រំដែនកំណត់សម្រាប់អ្នកសួរចម្លើយដែលគាត់តែងឡើងសម្រាប់ការទាញយកចម្លើយសារភាពដែលមានប្រសិទ្ធិភាពមានចែងជាពីរ ៈ មិនត្រូវសម្លាប់អ្នកទោស ឬក៏ធ្វើទារុណកម្មខ្សោយពេកដើម្បីឲ្យអ្នកទោសសារភាពឡើយ ។ អ្នកសួរចម្លើយដែលសម្លាប់អ្នកទោសក្នុងអំឡុងពេលធ្វើទារុណកម្មត្រូវបានរាយការណ៍ជូនថ្នាក់លើរបស់ ឌុច ប៉ុន្តែជាទូទៅអ្នកសួរចម្លើយនោះមិនដែលទទួលទោសអ្វីឡើយ ។

ក្រៅពីប្រភេទធ្វើទារុណកម្មដែល ឌុច អនុញ្ញាតឲ្យធ្វើ ឌុច ក៏បានទទួលស្គាល់ថា មានប្រភេទទារុណកម្មជាច្រើនទៀតដែលត្រូវបានប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានកំណត់ច្បាស់លាស់រួមមាន ការបង្ខំឲ្យផឹកទឹកនោម ស៊ីលាមក ការចោះនិងដកក្រចក ។ អ្នកទោសក៏ត្រូវបានបង្ខំឲ្យ«គោរព»សត្វឆ្កែពាក់មួកដែលមានរូប ហូជីមិញ និងវត្ថុគ្មានជីវិតដូចជា គ្រឿងសង្ហារឹម ដែលមានសណ្ឋានបែបបទ ជាការធ្វើទារុណកម្មលើផ្លូវចិត្ត ។ ប្រហែលជាអ្វីដែលអាក្រក់បំផុតនោះគឺថា អ្នកទោសក៏ត្រូវបានបង្ខំឲ្យចូលរួមក្នុង«ការពិសោធន៍ផ្នែកវេជ្ជសាស្ត្រ» ។ អ្នកទោសដែលមានជីវិតត្រូវបានបង្ខំឲ្យធ្វើការវះកាត់ ក្នុងគោលបំណងធ្វើការសិក្សាស្រាវជ្រាវពីកាយវិភាគសាស្ត្រ ហើយក៏ត្រូវបានយកមកសាកល្បងថ្នាំព្យាបាលថ្មីផងដែរ ។ ជាមួយគ្នានេះក៏មានការបូមឈាមពីអ្នកទោស ដើម្បីយកមកបញ្ចូលឈាមឲ្យកងទ័ពខ្មែរក្រហម ។ យ៉ាងហោចណាស់ អ្នកទោសរបស់មន្ទីរស-២១ប្រហែលជា១០០នាក់ បានស្លាប់ដោយសារតែការបូមឈាមចេញរហូតដល់«គ្មានសល់ឈាម» ។ ក្នុងការធ្វើកសិណសាក្សីដ៏ចម្លែកបន្តិចនេះ ឌុច បានរៀបរាប់ពីថ្ងៃមួយដែលសមាជិកបក្សជាន់ខ្ពស់ នួន ជា បានប្រគល់ថ្នាំឲ្យ ឌុច យកទៅឲ្យអ្នកទោសសាកល្បងដែល ឌុច គិតថាថ្នាំនោះគឺជាថ្នាំពុល ។ ឌុច ទំនងជាមានភាពរីករាយជាមួយនឹងខ្លួនឯង

ខណៈពេលធ្វើការរៀបរាប់ថា គាត់បានបើកគម្របដបថ្នាំ ហើយលាងសម្អាតវានឹងសំលី ដោយដាក់ម្សៅប្រភេទផ្សេងៗទៀតចូលទៅក្នុងដប ដើម្បី«ជួយសង្គ្រោះ»អ្នកទោស ។ ប៉ុន្តែសម្រាប់ នួន ជា និងអ្នកទោសវិញគិតថា ឧក្រិដ្ឋកម្មបានកំពុងតែប្រព្រឹត្តទៅវិញទេ ។ ចៅក្រម ឡាវែន៍ បានសួរព័ត៌មានបន្ថែមទាក់ទិននឹងហេតុការណ៍ដែលបានកើតឡើងមកលើអ្នកទោស ហើយដាក់ស្តែង ឌុច បានពន្យល់រៀបរាប់ពីរបៀបដែលអ្នកទោសទាំងនោះត្រូវបានសម្លាប់ យោងតាមដំណើរការជាប្រចាំរបស់មន្ទីរ ស-២១ ។ ការរៀបរាប់ទាំងអស់នេះមានន័យថា អ្នកទោសទាំងអស់បានរងនូវការធ្វើទារុណកម្មបន្ទាប់មកយកទៅសម្លាប់ ។ ចៅក្រម ឡាវែន៍ បានសួរថា «តើការប្រើប្រាស់ថ្នាំនេះ គឺជាវិធីសាស្ត្រធ្វើទារុណកម្មដែលស្រាលជាងគេឬ»? ឌុច បានពន្យល់ថា ប្រសិនបើ ឌុច បានប្រគល់ថ្នាំនោះទៅឲ្យអ្នកទោស ការស្លាប់របស់អ្នកទាំងនោះ «អាចនឹងធ្វើឡើងដោយដៃ ឌុច ផ្ទាល់» ។ ឌុច បានព្យាយាមគេចវេសមិនសម្លាប់មនុស្សដោយផ្ទាល់ ។ ចៅក្រម ឡាវែន៍ បានមើលទៅកាន់ ឌុច ដោយភាពភ្ញាក់ផ្អើលបន្ទាប់មកក៏សួរបន្ត ។

ដោយមូលហេតុថា ឌុច ក៏ទទួលរងការចោទប្រកាន់ពីបទរំលោភផ្លូវភេទក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀតដែលប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះទាំងមូលព្រមទាំងចៅក្រម ខាតរ៉ាយថ៍ បានផ្តោតហេតុការណ៍រំលោភដែលបានកត់ត្រាទុកនៅមន្ទីរស-២១ ។ ក្នុងអំឡុងពេលសួរចម្លើយអតីតអ្នកគ្រូបង្រៀនរបស់ ឌុច អ្នកទោសប្រុសម្នាក់បានរុកឈើចូលទៅក្នុងប្រដាប់ភេទរបស់អ្នកគ្រូនោះ ។ ឌុច បានរៀបរាប់ពីភាពខឹងសម្បា និងវន្ទត់របស់ខ្លួនក្រោយពីបានដឹងពីឧក្រិដកម្មនេះ ហើយក៏បានរៀបរាប់ថា គាត់បានរាយការណ៍ពីរឿងរំលោភនេះទៅកាន់ថ្នាក់លើរបស់គាត់ ប៉ុន្តែថ្នាក់លើទាំងនោះដូចជាមិនយកចិត្តទុកដាក់នឹងរឿងនេះឡើយ ។ ចៅក្រម ខាតរ៉ាយថ៍ ដែលមើលទៅដូចជាមានភាពសង្ស័យបានសួរ ឌុច ថា តើ ឌុច អាចធានាថា មិនមានការរំលោភផ្លូវភេទបែបនេះទៀតបានដោយរបៀបណាទៅ បើការសួរចម្លើយធ្វើឡើងមួយទល់នឹងមួយជាមួយអ្នកសួរចម្លើយ ដោយគ្មានការត្រួតពិនិត្យបែបនេះនោះ ។ ឌុច បានផ្តល់ជាការអធិប្បាយតែបន្តិចប៉ុណ្ណោះ ហើយក៏និយាយបន្ថែមថា អ្នកទោសខ្លួនឯងដឹងថា ប្រសិនបើគេប្រព្រឹត្តខុស គេនឹងត្រូវសម្លាប់ចោល ។

ការខ្វះខាតនូវការត្រួតពិនិត្យ និងការណែនាំលើអ្នកសួរចម្លើយនៅឯមន្ទីរស-២១ បានក្លាយជាប្រធានបទសំខាន់សម្រាប់ការសួរសំណួរពេញមួយថ្ងៃនេះ ។ ឌុច មាន«អំណាចគ្រប់គ្រង» ប៉ុន្តែ ឌុច ពឹងផ្អែកលើសមមិត្ត ហ៊ិ ដើម្បីគ្រប់គ្រងព័ត៌មានស្តីពីដំណើរប្រតិបត្តិការទូទៅរបស់មន្ទីរស-២១ ។ ឌុច បាន

គូសបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនដែលគិតអ្វីក្រៅពីចម្លើយសារភាពដែលទទួលបានពីការសួរចម្លើយនោះទេ ហើយភាគច្រើនមិនអើពើនឹងវិធីសាស្ត្រដែលអ្នកសួរចម្លើយបានប្រើប្រាស់ដើម្បីទាញយកចម្លើយសារភាព។ ប៉ុន្តែ ឌុច បានទទួលស្គាល់ថា គាត់គិតថាភាពត្រឹមត្រូវរបស់ចម្លើយសារភាព គឺ "៥០ភាគរយ" ជាព័ត៌មានពិតប្រាកដ។ ឧទាហរណ៍ ចំនួនអ្នកតំណាងឲ្យ កា.ហ្វេ.បេ និង សេ.អ៊ី.អា ជាច្រើននាក់ត្រូវបានរកឃើញនៅឯមន្ទីរស-២១ ក្រោយពេលដែល ឌុច បានបង្រៀនពីពាក្យកាត់ទាំងពីរនេះដល់ក្រុមសួរចម្លើយទាំងអស់។

## "ព្រះរាជអាជ្ញាដ៏ខ្លាំងក្លា" ប្រឆាំងនឹងមេធាវីការពារក្តី?

សង្គ្រាមពាក្យសម្តីមួយបានកើតឡើងរវាងភាគីទាំងអស់នៅក្នុងអង្គសវនាការថ្ងៃនេះ ក្រោយពីអង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះប្រគល់ថិរវេលារយៈពេល៣ម៉ោងឲ្យព្រះរាជអាជ្ញា ៣ម៉ោងឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង៤ម៉ោងឲ្យមេធាវីការពារក្តី ដើម្បីសួរសំណួរ ឌុច ទាក់ទិននឹងដំណើរប្រតិបត្តិការមន្ទីរស-២១។ ព្រះរាជអាជ្ញាបានទាមទារព័ត៌មានបញ្ជាក់ខ្លះៗពីអង្គជំនុំជម្រះដោយផ្អែកលើមូលដ្ឋានភាពជាប់ពាក់ព័ន្ធដែលថា រយៈពេល៣ម៉ោង អាចបង្កភាពលំបាកដល់ព្រះរាជអាជ្ញា។ ហ្រ្វង់ស៊័រ រូ មេធាវីការពារក្តីអន្តរជាតិបានឆ្លើយតបវិញថា ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដូចជា "មិនគោរព" ដល់ចៅក្រមទាល់តែសោះ ពីព្រោះថា ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនាំគ្នាសួរសំណួរសាក្សីសារជាថ្មីម្តងទៀត បន្ទាប់ពីអង្គជំនុំជម្រះបានសួរដោយម៉ត់ចត់ម្តងរួចទៅហើយ។ បន្ថែមលើនេះ រូ បានអះអាងថា យោងតាមគោលការណ៍ មេធាវីការពារក្តីគួរតែទទួលបានរយៈពេលសួរសំណួរសាក្សីដូចគ្នានឹងភាគីប្រឆាំងរបស់ខ្លួនដែលសំដៅទៅលើព្រះរាជអាជ្ញានិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ រូ បន្ថែមទៀតថា គាត់មិនបានធ្វើការរិះគន់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទេ ប៉ុន្តែមានបំណងចង់ពិភាក្សាពីភាពមិនស្មើគ្នានៃថិរវេលានេះ នាពេលក្រោយតាមរយៈបណ្តឹងឧទ្ធរណ៍។

ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពិតជាមានភាពខឹងសម្បាយ៉ាងខ្លាំងក្រោយពីបានស្តាប់ការនិយាយរៀបរាប់របស់ ហ្រ្វង់ស៊័រ រូ។ ព្រះរាជអាជ្ញាបានចាត់ទុកយោបល់របស់មេធាវីការពារក្តីថា "ជាមតិប្រឆាំង" ហើយបានអះអាងបន្ថែមទៀតថា ព្រះរាជអាជ្ញាមានកាតព្វកិច្ចផ្តល់ភស្តុតាងដាក់បន្ទុកឲ្យលើសពីមតិសង្ស័យ ដែលនេះគឺជាកាតព្វកិច្ចមួយដាច់ដោយឡែកពីកាតព្វកិច្ចរបស់ចៅក្រម។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនបានក្រោកឈរបង្ហាញពីទស្សនៈរបស់ខ្លួន ស្ដីពីតួនាទីចូលរួមក្នុងដំណើរការនីតិវិធីក្នុងនាមជាអង្គភាពឯករាជ្យមួយ មិនមែនជាផ្នែកមួយនៃ“ភាគីព្រះរាជអាជ្ញា” នោះទេ ។ ចៅក្រមហាក់បីដូចជាមិនមានការចាប់អារម្មណ៍នឹងការពិភាក្សាដេញដោលនេះទេ ហើយក៏បានបញ្ចប់ការពិភាក្សានេះភ្លាមដោយគ្មានមតិយោបល់អ្វីទាល់តែសោះ បន្ទាប់មកក៏បន្តដំណើរការនីតិវិធីទៅមុខទៀត ។